■改編自:新北市教育局
陪你快樂學柬埔寨語
□自編

108 年新北市各級學校東南亞語文競賽
團體朗讀文稿柬埔寨 語 國小組 B-1

ម្ហូបអាហារពិសេស

ម៉ាក់: ចុះពីយន្តហោះ តើអ្នកទាំងអស់គ្នាចង់ទៅញុំាអាហារថ្ងៃត្រង់
នៅហាងម្ហូបអាហារខ្មែរដែរឬទេ?

សុខា: តើម្ហូបអាហារមានខុសគ្នាអ្វីខ្លះដែលអាចញុំាបាន?

ម៉ាក់: មាននំបញ្ចុកសម្លខ្មែរ បាយសាច់ជ្រូកចៀន គុយទាវភ្នំពេញ
ហើយមានម្ហូបអាហារដែលខុសពីតៃវ៉ាន់ជាច្រើន កូនទាំងអស់
គ្នាអាចញុំាសាកល្បងមើល។

បងស្រី: តើជូរខ្លាំងដែរឬទេ?

ប្អូនស្រី: តើហិលដែរឬទេ?

ម៉ាក់: មានជូរតិចៗ ប៉ុន្តែមិនជូរពេកទេ។

ម៉ាក់: មានម្ហូបអាហារខ្លះហិលតិចៗ ក៏មានអាអត់ហិលដែរ
សុទ្ធតែអាចញុំាបាន។

សុខា: តើមានភេសជ្ជៈទេ?

ម៉ាក់: មានតា ប៉ុន្តែទាល់ញុំាអាហាររួចទើបអាចផឹកបាន។

(ពោល) : ញុំាអាហារថ្ងៃត្រង់រួច មួយគ្រួសារនាំគ្នាទៅ
ដើរលេងផ្សារធំថ្មីទាំងអស់គ្នា។

ប្អូនស្រី: ខ្ញុំមិនដែលឃើញទេ តើនោះជាអ្វី?

ម៉ាក់: នោះជាផ្លែឈូក មានគ្រាប់ឈូកនៅខាងក្នុងអាចញ៉ាំ
ផៅបាន នៅតែវ៉ាន់ មានតែឃើញគ្រាប់ឈូកនិងមឹម
ឈូកនៅក្នុងផ្សារ។

បងស្រី: ម៉ាក់ តើនេះផ្លែឈើអ្វី?

ម៉ាក់: នោះគឺជាផ្លែសៅមៅ បន្តិចទៀតម៉ាក់ត្រូវទិញផ្លែទឹក
ដោះគោនិងចេកពងមាន់ថែមទៀតយកទៅផ្ទះយាយ។

សុខា: ចេកនឹងតូចមែនទែន!

(ពោល) : ម៉ាក់និយាយសើច

ម៉ាក់: ហាសហា! នោះជាចេកពងមាន់ មិនមែនជាចេកធម្មតាទេ។

បងស្រី ប្អូនស្រី: ហាសហា ហាសហា ហាសហា

(ពោល) : មួយគ្រួសារទាំងអស់គ្នាយូរផ្លែឈើជិះរតយន្ត
ធ្វើដំណើរទៅផ្ទះយាយ។